# កត្តាជោគជ័យនៃការរៀបចំដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ សម្រាប់រដ្ឋបាលស្រុក

****************

## ១. តើអ្វីទៅជាដីកា?

ដីកា គឺជាប្រភេទលិខិតបទដ្ឋានគតិយុត្តមួយ មានលក្ខណៈជាបទបញ្ជាទូទៅ និងឯកត្តភូត ដែលត្រូវបានអនុម័ត ដោយក្រុមប្រឹក្សា ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដីកា ដែមានលក្ខណៈជាបទបញ្ជាទូទៅ គឺជាការណែនាំពីការអនុវត្ត ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងជាការណែនាំការអនុវត្តកិច្ចការដែលស្ថិតនៅក្នុងដែនសម្តកិច្ច របស់ក្រុមប្រឹក្សាស្រុក។ ក្រុមប្រឹក្សាស្រុកមានសិទ្ធអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិតាមរយៈ ការដាក់ចេញនូវដីកា និងសេចក្តីសម្រេចខាងប្រតិបត្តិតាមរយៈការដាក់ចេញនូវសេចក្តីសម្រេចក្នុងកិច្ចប្រជុំរបស់ខ្លួន។

## ២. តើដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅមានដំណើការរៀបចំយ៉ាងដូចម្តេច?

ប្រជាពលរដ្ឋអាចស្នើសុំ ឬលើកឡើងនូវកង្វល់ បញ្ហានានារបស់ពួកគេទៅកាន់អាជ្ញាធរមូលដ្ឋានដើម្បីឆ្លើយតបតាមរយៈ គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្រុក វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សា(D&C) និងកម្មវិធីសាធារណៈផ្សេងៗទៀត។ បញ្ហាទាំងនោះត្រូវសម្រេច និងជ្រើសរើសដោយក្រុមប្រឹក្សាស្រុក ដើម្បីឆ្លើយតបនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាស្រុកបានចាត់អាទិភាព បញ្ហាសំខាន់ចំនួន២ ទាក់ទងនឹង ការងារគ្រប់គ្រងសំរាមសំណល់រឹងនៅក្នុងស្រុកបាណន់ និងស្រុកមោងឬស្សី និងបញ្ហាសុវត្ថិភាពចំណីអាហារនៅតាមសាលារៀននៅស្រុកថ្មគោល។ រដ្ឋបាលស្រុកទាំង៣ បានឱ្យមានការរៀបចំឬដាក់ចេញដីកាដើម្បីដោះស្រាយ និងឆ្លើយតបទៅនឹងបញ្ហាទាំងពីរខាងលើ។ ដូចនេះដីកាចំនួន ៣ ត្រូវបានពិភាក្សា អនុម័ត និងដាក់ចេញដោយក្រុមប្រឹក្សាស្រុកដើម្បីធ្វើការអនុវត្ត ដែលវាត្រូវចំណាយពេលប្រហែល ចន្លោះពី ៦ ទៅ ៧ ខែ សម្រាប់រដ្ឋបាលស្រុកនីមួយៗ ដើម្បីទទួលបានការសម្រេច និងអនុម័តចុងក្រោយរបស់ក្រុមប្រឹក្សាស្រុក។

យោងទៅតាមអនុក្រឹត្យលេខ ២៨៦ ស្តីពីនីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីកា របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ ព្រមទាំងឯកសារបច្ចេកទេសនៃការរៀបចំដីកា គឺមាន៤ជំហាន សម្រាប់ការរៀបចំដីកាដែលមាន លក្ខណៈជាបទញ្ញាទូទៅ។ ជំហានទាំងនោះមាន៖ ១)កំណត់តម្រូវការនៃការដាក់ចេញដីកា ២)រៀបចំសេចក្តីព្រាងដីកា ៣)ការពិគ្រោះយោបល់ និងបិទផ្សាយជាសាធារណៈ និង ៤)ការពិនិត្យ និងអនុម័តលើដីកា។

### ជំហានទី១) កំណត់តម្រូវការនៃការដាក់ចេញដីកា

នៅពាក់កណ្តាលឆ្នាំ ២០១៩ ក្រុមប្រឹក្សាស្រុកបាណន់ ស្រុកថ្មគោល និងស្រុកមោងឫស្សី បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ (D&C) ប្រចាំឆ្នាំរបស់ខ្លួននៅតាមឃុំទាំងអស់ ដើម្បីផ្សព្វផ្សាយអំពីសមិទ្ធិផលដែលក្រុមប្រឹក្សាសម្រេចបានក្នុងឆ្នាំ ជូនប្រជាពលរដ្ឋ ព្រមទាំងផែនការជាអាទិភាពដែលក្រុមប្រឹក្សានឹងអនុវត្តនៅក្នុងឆ្នាំបន្ទាប់ និងពិគ្រោះយោបល់ដើម្បីស្វែងយល់អំពី សំណើ សំណូមពររបស់ប្រជាពលរដ្ឋ។ ជារួមស្រុកទាំងបីខាងលើនេះ បានរៀបចំវេទិកាប្រចាំឆ្នាំចំនួន ១៨វេទិកា ក្នុងនោះ ស្រុកបាណន់មានចំនួន ៤វេទិកា ស្រុកមោងឫស្សីមានចំនួន ៩ វេទិកា និងស្រុកថ្មគោលមានចំនួន ៥ ដែលមានអ្នកចូលរួមប្រមាណ ១.៨០០នាក់។ ក្រុមប្រឹក្សាបានប្រមូលបានបញ្ហា ឬតម្រូវការសរុបប្រហែល ២៥០បញ្ហា ឬតម្រូវការ។ បញ្ហាទាំងនោះមានទាក់ទងនឹងសេវា សង្គម (មានដូចជា ការងារអប់រំ សុខភាព

សំរាម ......) សេវារដ្ឋបាល (ដូចជា ការចុះបញ្ជីអត្រានុកូលដ្ឋាន ការផ្តល់សេវាអត្តសញ្ញាណប័ណ្ណ... ) និងការងារហេដ្ឋារចនាសម្ព័ន្ធ (មានដូចជា ការតបណ្តាញអគ្គិសនី ផ្លូវថ្នល់ ជាដើម ......)។ បញ្ហាពាក់ព័ន្ធនឹងសេវាសង្គមត្រូវបានពិភាក្សា និងចាត់អាទិភាពដោយរដ្ឋបាលស្រុក ដើម្បីមានវិធានការដោះស្រាយ និងឆ្លើយតប។ បញ្ហាការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ដែលបានលើកឡើងនៅក្នុងស្រុកបាណន់ និងស្រុកមោងឫស្សី និងបញ្ហាកង្វះអនាម័យនៅតាមសាលារៀនដែលបានលើកឡើងនៅក្នុងស្រុកថ្មគោលត្រូវបានជ្រើសរើស និងត្រូវបានចាត់ជាបញ្ហាអាទិភាព។ ដោយឡែកបញ្ហាទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ សេវាសង្គម និងសេវារដ្ឋបាលដែលនៅសល់ ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីវិនិយោគរបស់រដ្ឋបាលស្រុក និងរដ្ឋបាលឃុំដើម្បីសម្របសម្រួលដោះស្រាយ។ បញ្ហាសំរាមសំណល់រឹងទីប្រជុំជន គឺមានការទាក់ទងនឹងក្រុមហ៊ុនប្រមូលសំរាម ដែលក្នុងនោះមិនទាន់មានកម្រៃសេវាប្រមូលសំរាមបានច្បាស់លាស់នៅឡើយ គឺយកទៅតាមកម្រៃតាមការចរចារប៉ុណ្ណោះ ដែលធ្វើឱ្យមាន ការតវ៉ាជាច្រើនពីប្រជាពលរដ្ឋ ។ អ្នកប្រមូលក៏ប្រមូលសំរាមឬក្រុមហ៊ុនប្រមូលសំរាម ក៏នៅតែប្រមូលសំរាមពុំទាន់ពេលវេលា និងទៀងទាត់នៅឡើយ។ ម៉្យាងទៀតប្រជាពលរដ្ឋដែលជាអ្នកបង្កើតសំរាមមួយចំនួន មិនព្រមបងថ្លៃសេវាប្រមូលសំរាម និងនៅតែបន្តបោះចោលសំរាមសំណល់រឹងនៅតាមដងផ្លូវ ទីសាធារណៈ បើទោះបីមានការអប់រំផ្សព្វ ផ្សាយជាច្រើនលើកច្រើនសារយ៉ាងណាក៏ដោយ។

ជាការឆ្លើយតបទៅនឹងបញ្ហាជាក់លាក់ដែលបានកំណត់ខាងលើ រដ្ឋបាលស្រុកបាណន់ និងស្រុកមោងឫស្សី បានជ្រើសរើសក្រុមហ៊ុនប្រមូលសំរាមថ្មី នៅដើមឆ្នាំ ២០២០។ ស្រុកមោងឫស្សីបានចុះហត្ថលេខា ជាមួយក្រុមហ៊ុន ដោយមានកិច្ចសន្យារយៈពេល ១០ឆ្នាំបន្ទាប់ពីអោយក្រុមហ៊ុនសាកល្បងផ្តល់សេវាបាន៣ខែ ខណៈស្រុកបាណន់ បានធ្វើការអនុញ្ញាត្តិឱ្យក្រុមហ៊ុនប្រមូលសាកល្បង បណ្តោះអាសន្ន។ រដ្ឋបាលស្រុកនីមួយៗបានរៀបចំនូវ សំណើរគម្រោងស្តីពីការគ្រប់គ្រងសំរាមសំណល់រឹង និងលើកកម្ពស់ សុខមាលភាពកុមារនៅតាមសាលារៀន ដោយផ្តោតលើះ ទី១) ដាក់ចេញនូវដីកា ទី២) រៀបចំសេចក្តីណែនាំស្តីពីការគ្រប់គ្រងសំរាម និងទី៣) ធ្វើការអប់រំដល់កុមារនិងពលរដ្ឋនៅតាមមូលដ្ឋាន និងសាលារៀនតាមរយៈការផ្សព្វផ្សាយចល័ត និងដំឡើងផ្ទាំងប៉ាណូ។ ដើម្បីអោយការអនុវត្តន៍ការងារបានរលូនរដ្ឋស្រុកនីមួយៗបានបង្កើតក្រុមការងារជាក់លាក់មួយដែលមានសមាជិកប្រហែល ២៥នាក់មានសមាសភាពមកពីក្រុមប្រឹក្សាស្រុក គណៈអភិបាល រដ្ឋបាលឃុំ ការិយាល័យជំនាញ និងអង្គភាពពាក់ព័ន្ធ។ ក្រុមការងារនេះនឹងទទួលខុសត្រូវលើការរៀបចំសេចក្តីព្រាងដីកា និងអនុវត្តគម្រោង។ សមាជិកទាំងអស់ ក៏បានទទួលការបណ្តុះបណ្តាលស្តីពីការរៀបចំដីកា តាមសំណើរបស់រដ្ឋបាលស្រុក ដោយមានការគាំទ្រពីទីប្រឹក្សា DAR។

**ជំហានទី២) រៀបចំសេចក្តីព្រាងដីកា**



*រូបភាពទី 1៖ កិច្ចប្រជុំព្រាងដីកា នៅស្រុកថ្មគោល*

ដើម្បីរៀបចំសេចក្តីព្រាងដីកា ស្រុក មោងឫស្សី និងស្រុកថ្មគោល បានធ្វើការសិក្សាស្រាវជ្រាវបន្ថែម លើបញ្ហា ដែលបានជ្រើសរើស។ ដោយឡែក ស្រុកបាណន់ គឺសម្រេច យកទិន្នន័យដែលមានស្រាប់ ក្នុងឆ្នាំ២០១៨ ធ្វើជាទិន្នន័យដើមគ្រា។ ក្រុមការងារ បានសិក្សាលំអិត នូវឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម និងសុវត្ថិភាពចំណីអាហារនៅតាមសាលារៀន។ លើសពីនេះទៅទៀតក្រុមការងារ បានពិគ្រោះយោបល់ជាមួយវិស័យឯកជន (អ្នកប្រមូល

សំរាម) ស្តីពីការកំណត់កម្រៃសេវាប្រមូលសំរាម ដោយផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ។ ទិន្នន័យទាំងអស់ត្រូវបានវិភាគ និងបកស្រាយដើម្បីរៀបចំសេចក្តីព្រាងបឋមនៃដីកា។ មេរៀនបទពិសោធន៍ល្អៗ ទាក់ទងនឹងការរៀបចំដីកា និងការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ក្រុងបាត់ដំបង ក៏ត្រូវបានចែករំលែកផងដែរជាមួយស្រុកមោងឫស្សី។

នៅក្នុងដំណាក់រៀបចំនេះ សេចក្តីព្រាងដីកា ត្រូវបានពិភាក្សានៅក្នុងក្រុមការងារ និងអ្នកពាក់ព័ន្ធដើម្បីផ្តល់នូវធាតុចូលបន្ថែមក្នុងដំណើរការរៀបចំនេះ។ សម្រាប់ក្រុមការងារស្រុកមោងឫស្សីបានរៀបចំ កិច្ចប្រជុំចំនួន៣លើក គឺលើកទី១ ត្រូវបានរៀបចំឡើងដើម្បីពិភាក្សាខ្លឹមសារទាំងស្រុងនៃដីកា ថាតើត្រូវមានអ្វីខ្លះ ត្រូវកែ សម្រួល ពិនិត្យអក្ខរាវិរុទ្ធ និងឯកសារយោង។ កិច្ចប្រជុំលើកទី២ ជាមួយការិយាល័យជំនាញ ក្រុមហ៊ុនប្រមូលសំរាម ដើម្បីពិភាក្សាផ្តោតលើតួនាទី និងទំនួលខុសត្រូវរបស់អ្នកប្រើប្រាស់សេវាកម្ម និងអ្នកផ្តល់សេវា។ ប្រជុំលើកទី ៣ ជាមួយការិយាល័យ និងសមាជិកក្រុមប្រឹក្សា ដើម្បីពិភាក្សាអំពីតួនាទី ទំនួលខុសត្រូវ របស់អាជ្ញាធរពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យអក្ខរាវិរុទ្ធ និងយន្តការនៃការពិន័យ។ ដោយឡែកក្រុមការងារ នៅស្រុកបាណន់បានរៀបចំកិច្ចប្រជុំចំនួនពីរលើក នៅក្នុងក្រុមការងារបច្ចេកទេសៈ ទី១ កិច្ចប្រជុំបែងចែកភារកិច្ច និង កំណត់ខ្លឹមសារសំខាន់ៗនៃដីកា និងលើកទី២ កិច្ចពិភាក្សា និងឯកភាពលើសេចក្តីព្រាងបឋម។ ព្រមទាំងមានកិច្ច ប្រជុំក្រុមការងារទាំងមូលចំនួន ១លើកផ្សេងទៀត ដើម្បីពិនិត្យ និងលើកយោបល់លើខ្លឹមសារទាំងមូលនៃដីកា។ សម្រាប់ស្រុកថ្មគោល មានកិច្ចប្រជុំចំនួន១លើក នៅក្នុងក្រុមការងារ ដើម្បីរៀបចំសេចក្តីព្រាងបឋមដីកា សុវត្ថិភាពចំណីអាហារតាមសាលា។ សម្រាប់ស្រុកថ្មគោលបានរៀបចំកិច្ចប្រជុំតែមួយលើកនៅក្នុងដំណាក់កាលនេះ ដោយសារតែខ្លឹមសារដីកានៃសុវត្ថិភាពចំណីអាហារតាមសាលារៀន ពុំសូវមានលក្ខណៈស្មុកស្មាញដូចការងារគ្រប់គ្រងសំរាមសំណល់រឹង។

បន្ទាប់ពីដីកាត្រូវបានឯកភាព នៅក្នុងក្រុមការងារ គណៈអភិបាលបានរៀបចំកិច្ចប្រជុំមួយ ដើម្បីពិនិត្យ និងផ្តល់យោបល់។ គណៈអភិបាលបានលើកយោបល់ជាច្រើនទាក់ទងនឹង ឯកសារយោង មាតិកាឬខ្លឹមសារដីកា អក្ខរាវិរុទ្ធមួយចំនួន និងកំណត់ទោសបញ្ញត្តិជាដើម។ ក្រុមការងារបច្ចេកទេស បានកែសំរួលទៅតាមយោបល់របស់គណៈអភិបាល និងបានដាក់ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាស្រុកដើម្បីពិនិត្យ និងឯកភាពលើសេចក្តីព្រាងបឋម។ សេចក្តីព្រាងនេះត្រូវបានឯកភាពដោយក្រុមប្រឹក្សាស្រុក នៅក្នុងកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ខ្លួន។ ក្នុងកិច្ចប្រជុំនេះក៏មានការអញ្ជើញចូលរួមផងដែរនូវ ក្រុមហ៊ុនប្រមូលសំរាម អាជ្ញាធរមូលដ្ឋាន និងក្រុមការងារបច្ចេកទេស។ ក្រុមការងារបច្ចេកទេសជាអ្នកឆ្លើយតប និងបកស្រាយ នូវរាល់ សំនួរ និងយោបល់ របស់ក្រុមប្រឹក្សា។ ក្រុមប្រឹក្សាស្រុកទាំងបី បានណែនាំឱ្យក្រុមការងារ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយពលរដ្ឋ និងអ្នកពាក់ព័ន្ធ បន្តទៀតមុនពេលអនុម័ត។

**ជំហានទី៣) ការពិគ្រោះយោបល់ និងបិទផ្សាយជាសាធារណៈលើសេចក្តីព្រាងដីកា**

ការដាក់ចេញដីកា របស់ក្រុមប្រឹក្សាអាចមានផលប៉ះពាល់ផ្ទាល់ទៅលើជីវភាពរស់នៅរបស់ប្រជាជន។ ដើម្បីធានាថាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្រុមប្រឹក្សាស្រុក ត្រូវពិគ្រោះយោបល់ជាមួយពលរដ្ឋនៅដំណាក់កាលដំបូង នៃដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ ដោយទទួលបាននូវអនុសាសន៍ពីក្រុមប្រឹក្សា ក្រុមការងារបានរៀបចំកិច្ចប្រជុំដើម្បីរៀបចំកាលវិភាគ និងវិធីសាស្រ្តក្នុងការ



*រូបភាពទី ២៖ វេទិកាពិគ្រោះយោបល់សេចក្តីព្រាងដីកានៅស្រុកបាណន់*

ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ដោយបែងចែកជាក្រុមតូចៗ កំណត់តួនាទីនិងការទទួលខុសត្រូវ និងរៀបចំរបៀបវារៈ។ រដ្ឋបាលស្រុកទាំងបី បានរៀបចំវេទិកាពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្រុកវិស័យឯកជន សិស្សានុសិស្ស នាយកសាលា និងអាជ្ញាធរមូលដ្ឋាន លើខ្លឹមសារទាំងស្រុងនៃដីកា។ ជាក់ស្តែងរដ្ឋបាល ស្រុកបាណន់បានរៀបចំវេទិកាពិគ្រោះយោបល់ចំនួន ៨វេទិកា ដោយមានអ្នកចូលរួមសរុប ៣៥៥ នាក់ (ស្រី ១១៩ នាក់) ដែលរួមមានប្រជាពលរដ្ឋ អាជីវករ អ្នកលក់ដូរ នាយកសាលា សិស្សានុសិស្ស វិស័យឯកជន អាជ្ញាធរមូលដ្ឋាន និងអង្គការសង្គមស៊ីវិលក្នុងស្រុក។ សម្រាប់ ស្រុក មោងឬស្សី បានរៀបចំវេទិកាគ្រោះយោបល់ចំនួន ៩វេទិកា ជាមួយវិស័យឯកជនប្រជាពលរដ្ឋ (អាជីវកម្ម និងមិនមានអាជីវកម្ម) សង្គមស៊ីវិល និងទីភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត (ក្រុមប្រឹក្សាចាប់ពីថ្នាក់ឃុំ និងតំណាងភូមិ)។ ដោយឡែកស្រុកថ្មគោលបានរៀបចំចំនួន ៦វេទិកា នៅតាមសាលារៀន ដោយមានអ្នកចូលរួមសរុបចំនួន ៣០០នាក់ មកពីអង្គភាពភូមិ សិស្សានុសិស្ស អាណាព្យាបាល អ្នកលក់ដូរ និងសង្គមស៊ីវិល។ លើសពីនោះ ក៏មានការពិគ្រោះយោបល់ជាមួយ មន្ទីអប់រំយុវជន និងកីឡាផងដែរលើខ្លឹមសារនៃដីកានេះ។



*រូបភាពទី ៣៖ ការបិទផ្សាយសេចក្តីព្រាងដីកា នៅ ស្រុកមោងឬស្សី*

បន្ថែមលើសពីនោះទៅទៀត សេចក្តីព្រាងដីកា នេះក៏ត្រូវបានផ្សព្វផ្សាយផងដែរ តាមរយៈ ក្តាខៀនព័ត៌មានសារធារណៈ ដោយមានរយៈពេល ១០ថ្ងៃ។ ការបិទផ្សាយជាសាធារណៈនេះ ត្រូវបានរៀបចំ ឡើងក្នុងគោលបំណងឱ្យពលរដ្ឋអាចពិនិត្យមើល និងលើកយោបល់ លើខ្លឹមសារដីកា។ ក៏ប៉ុន្តែ មិនមានពលរដ្ឋ ឬអ្នកពាក់ព័ន្ធ ណាម្នាក់ បានផ្តល់យោបល់លើខ្លឹមសារដីកា ដែលបាន បិទផ្សាយនេះទេ។

ដំណាក់កាលចុងក្រោយ ក្នុងជំហានទី៣នេះ គឺកិច្ចប្រជុំបូកសរុប លទ្ធផលនៃការរៀបចំវេទិកាពិគ្រោះយោបល់ ដោយមានការអញ្ជើញចូលរួមពីសមាជិកក្រុមការងារ និងអ្នកពាក់ព័ន្ធ។ លទ្ធផលនៃការរៀបចំវេទិកាពិគ្រោះយោបល់ ត្រូវបានលើកយកមកពិភាក្សា នឹងរៀបចំជារបាយការណ៍ ដើម្បីដាក់ជូនគណៈអភិបាល និងក្រុមប្រឹក្សាស្រុក។

**ជំហានទី៤) ការពិនិត្យ និងអនុម័តលើដីកា**



*រូបភាពទី ៤៖ កិច្ចប្រជុំក្រុមប្រឹក្សាស្រុក ដើម្បីអនុម័តដីកា ស្រុកបាណន់*

មានពីរដំណាក់កាល សម្រាប់ការពិនិត្យ និងអនុម័តលើសេចក្តីព្រាងដីកា។ ដំណាក់កាលដំបូងគឺការពិនិត្យ និងផ្តល់យោបល់ដោយ គណៈអភិបាល នៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ខ្លួន។ បន្ទាប់ពីទទួលបាន ការផ្តល់យោបល់ពីគណៈអភិបាល ក្រុមការងារបានធ្វើរបាយការណ៍ ដាក់ជូនក្រុមប្រឹក្សាស្រុកដើម្បីអនុម័ត។ ក្រុមការងារបានចាត់

តាំងអ្នកទទួលខុសត្រូវម្នាក់ ដែលជាអ្នកជំនាញខាងសំរាម និងអប់រំ ឱ្យបង្ហាញសេចក្ដីព្រាងចុងក្រោយនៃដីកា នៅក្នុងអង្គប្រជុំក្រុមប្រឹក្សាស្រុក។ ដំណាក់កាលចុង ក្រោយគឺ ការពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាស្រុកនៅក្នុងការប្រជុំក្រុមប្រឹក្សាសាមញ្ញ ឬវិសាមញ្ញរបស់ខ្លួន។ នៅស្រុកបាណន់ដីកាត្រូវបានអនុម័តដោយក្រុមប្រឹក្សាស្រុកក្នុងការប្រជុំប្រចាំខែលើកទី ១៨ ខណៈក្រុមប្រឹក្សាស្រុកមោង ឬស្សី និង ថ្មគោល បានអនុម័តក្នុងកិច្ចប្រជុំប្រចាំខែលើកទី ២០ របស់ខ្លួន។

បន្ទាប់ពីទទួលបានការអនុម័តដោយក្រុមប្រឹក្សាស្រុក ក្រុមការងារនៃរដ្ឋបាលស្រុកនីមួយៗ បានរៀបចំកែសម្រួលទៅតាមយោបល់របស់ក្រុមប្រឹក្សា និងដាក់ជូនប្រធានក្រុមប្រឹក្សាដើម្បីចុះហត្ថលេខា ក្នុងនាមក្រុមប្រឹក្សាស្រុកទាំងមូល។ ជាចុងក្រោយរដ្ឋបាលស្រុក បានញូនដីកាទាំងស្រុក ដើម្បីស្នើសុំពិនិត្យ នីត្យានុគោលភាពពីរដ្ឋបាលខេត្ត។

## ៣. ការពិភាក្សា និងសេចក្ដីសន្និដ្ឋាន

ដីកាដែលមានលក្ខណៈជាបទបញ្ញាទូទៅចំនួន ៣ ទាក់ទងនឹងការងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន និងសុវត្ថិភាពចំណីអាហារនៅតាមសាលារៀន ត្រូវបានអនុម័ត និងដាក់ចេញឱ្យអនុវត្ត ដោយក្រុមប្រឹក្សាស្រុកបាណន់ ស្រុកថ្មគោល និងស្រុកមោងឬស្សី ដោយអនុលោមតាមក្របខ័ណ្ឌគតិយុត្ត និងឯកសារបច្ចេកទេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ កិច្ចការងារចម្បងៗនៃដំណើរការរៀបចំដីកាគឺ ១) កំណត់ឱ្យបាននូវសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ ដែលត្រូវការឬសំណូមពរ តាមវេទិកាក្រុមប្រឹក្សា និងការប្រជុំសាធារណៈផ្សេងៗ ២) បង្កើតក្រុមការងារនិងចាត់តាំងមន្ត្រីជំនាញដើម្បីរៀបចំសេចក្ដីព្រាងដីកា ៣) សិក្សាស្រាវជ្រាវ ក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត និង ឯកសារបច្ចេកទេស ៤) ធ្វើការប្រមូលទិន្នន័យដើមគ្រាពីតម្រូវការនៃការរៀបចំដីកា ៥) ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ វិស័យឯកជន អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ពាក់ព័ន្ធលើខ្លឹមសារដីកា ៦) រៀបចំកិច្ចប្រជុំនៅក្នុងក្រុមការងារយ៉ាងតិចចំនួន៣លើក ដើម្បីរៀបចំសេចក្ដីព្រាងបឋម រៀបចំផែនការពិគ្រោះយោបល់ និងកិច្ចប្រជុំបូកសរុប និង ៧) រៀបចំកិច្ចប្រជុំគណៈអភិបាល និងក្រុមប្រឹក្សាស្រុក ដើម្បីពិនិត្យផ្ដល់យោបល់ និងអនុម័ត។ នៅពេលដំណើការពិគ្រោះ យោបល់ រដ្ឋបាលស្រុកនីមួយៗ បានប្រើវិធីសាស្ត្រផ្សេងៗពីគ្នា ក្នុងដំណាក់កាលពិគ្រោះយោបល់វត្តមានរបស់គណៈអភិបាល និងប្រធានក្រុមប្រឹក្សាមានសារៈសំខាន់បំផុត និងបានស្ដាប់នូវមតិយោបល់របស់ប្រជាពលរដ្ឋ។ ស្រុកបាណន់បានធ្វើការពិគ្រោះ ៨លើក ដោយមិនបានធ្វើការបែងចែក ទៅតាមប្រភេទនៃអ្នកចូលរួមទេ ខណៈស្រុកមោងឬស្សី បានរៀបចំ ៩វេទិកា ដោយធ្វើការបែងចែកប្រភេទនៃក្រុមអ្នកចូលរួម ដូចជាក្រុមវិស័យឯកជន ក្រុមប្រជាពលរដ្ឋជាដើម ។ល។

ដើម្បីសំរេចបាននូវសកម្មភាពខាងលើរដ្ឋបាលស្រុកត្រូវ មានព័ត៌មាននិងឯកសាគ្រប់គ្រាន់ កំណត់ពេលវេលាបានច្បាស់លាស់ ចាត់តាំងមន្ត្រីជំនាញទទួលបន្ទុកលើប្រធានបទដែលបានជ្រើសរើស និងមានការចូលរួមយ៉ាងសកម្មផងដែពីគណៈអភិបាល និងប្រធានក្រុមប្រឹក្សាស្រុក។ គណៈអភិបាល និងមន្ត្រីជំនាញក៏ត្រូវមានការតាំងចិត្តខ្ពស់ និងចំណេះដឹងទូលំទូលាយទៅលើប្រធានបទដែលបានជ្រើសរើសផងដែរ។